# បេឡាជាតិរបបសន្តិសុខសង្គម
## (ប.ស.ស)
### ខិត្តប័ណ្ណ សម្រាប់កម្មករនិយោជិត
### ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ)

ទំនាក់ទំនងមកប.ស.ស៖
- ទូរស័ព្ទមកលេខ ១២៨៦ ( Call ចូលគ្រប់ប្រព័ន្ធដោយមិនកាត់ប្រាក់) ករណីសង្គ្រោះបន្ទាន់ គ្រោះថ្នាក់ចរាចរណ៍ ដួលសន្លប់ និងករណីផ្សេងៗ...
-Facebook ប.ស.ស៖ បេឡាជាតិរបបសន្តិសុខសង្គម

## ដើម្បីជួយសម្រួលការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

បេឡាជាតិរបបសន្តិសុខសង្គម ក៏មានគណៈកម្មការ និងក្រុមការងារជំនាញមួយចំនួនដើម្បីជួយកម្មករនិយោជិត រួមមាន៖

- គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស ជួយផ្សះផ្សាវិវាទដែលទាក់ទងនឹងការអនុវត្តរបស់ប.ស.ស។
- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ជួយទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតមានក្នុងពេលកម្មករនិយោជិតធ្វើដំណើរ។
- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត ជួយកែលំអលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ និងលក្ខខណ្ឌការងារ ឲ្យកាន់តែល្អនៅកន្លែងការងារ។

បញ្ជាក់៖ សូមទំនាក់ទំនង ប.ស.ស ករណីមានវិវាទ ឬបណ្តឹងលើបញ្ហារបស់ ប.ស.ស ករណីមានគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត កម្មករសន្លប់ និងករណីផ្សេងៗ តាមរយៈលេខ ទូរស័ព្ទបន្ទាន់ ១២៨៦។

# និយមន័យ៖ ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ)

## កន្លែងការងារ

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការទោះដោយហេតុយ៉ាង ណាក៏ដោយ ហើយទោះមាន កំហុសពីកម្មករ និយោជិត ឬ គ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើ រូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយក សហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តី ឥតឈ្នួលក្តីកាន់មុខងារអ្វីនៅទីកន្លែង ណាក៏ដោយ ។

## ពេលធ្វើដំណើរ

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូប កាយ កម្មករនិយោជិត ក្នុងពេលដែលសាមី ខ្លួនធ្វើដំណើរ ពីលំនៅស្ថាន ខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការឬវិល មកវិញ ដោយ គ្មាន វាង ទៅកន្លែងផ្សេង ជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការ ងារ ដែល គេត ម្រូវ ឱ្យទៅ ។







គ្រោះថ្នាក់ការងារ



## សិទ្ធិទទួលបានតាវកាលិក

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុង ប.ស.ស មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជន ទទួលរងហានិភ័យការងារ ។

## ជំងឺវិជ្ជាជីវៈ

ជំងឺដែលបណ្តាលមកវិជ្ជាជីវៈ រួមមានមុខរបរប្រើកំលាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតីដែលនាំឱ្យអ្នកធ្វើការ កើតជំងឺផ្សេងៗ។



## និយមន័យតាវកាលិក

តាវកាលិក គឺជាប្រាក់ វត្ថុ ឬសេវាដែលត្រូវផ្តល់ឱ្យដល់សមាជិក ប.ស.ស នៅពេលចាស់ជរា ទុព្វលភាព និងនៅពេលទទួលរងហានិភ័យការងារទៅតាមកាលកំណត់មួយ។

## ការជូនដំណឹងហានិភ័យការងារ

**+ កម្មករនិយោជិត៖**

-ត្រូវជូនដំណឹងទៅរដ្ឋបាលសហគ្រាស គ្រឹះស្ថាន

-ឬជូនដំណឹងមក ប.ស.ស តាមលេខទូរស័ព្ទបន្ទាន់ ១២៨៦ (មិនគិតថ្លៃសេវាគ្រប់ប្រព័ន្ធ) ។

**+ និយោជក ឬអ្នកតំណាងបន្ទាប់ពីទទួលបានព័ត៌មានករណីកម្មករនិយោជិត៖**

-ជូនដំណឹងបន្ទាន់មក ប.ស.ស តាមរយៈលេខ ១២៨៦ ដើម្បីជួយសម្របសម្រួលជនរងគ្រោះទៅមន្ទីរពេទ្យ

-ផ្ញើរបាយការណ៍ជាបឋមមក ប.ស.ស តាមរយៈ

Email address: benefit@nssf.gov.kh

-ត្រូវបញ្ជូនរបាយការណ៍ហានិភ័យការងារ និង ឯកសារពាក់ព័ន្ធមក ប.ស.ស ក្នុងរយៈពេលយ៉ាងយូរ ៤៨ម៉ោង នៃថ្ងៃធ្វើការ ។

# តាវកាលិក (អត្ថប្រយោជន៍) ហានិភ័យការងារដែលកម្មករនិយោជិតទទួលបាន៖

## ១. ការផ្តល់សេវាសង្គ្រោះបន្ទាន់

ត្រូវបានផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយ ប.ស.ស ។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់ ប.ស.ស ។



## ២-ការផ្តល់សេវាថែទាំ និងការព្យាបាល

- ត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយ ប.ស.ស
- ក្នុងករណីដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសំភារៈឧបករណ៍ ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាល ជនរងគ្រោះ ឬអ្នកតំណាង អាចទាមទារមក ប.ស.ស ដើម្បីធ្វើការទូទាត់សងវិញបាន លុះត្រាណាតែមានវេជ្ជបញ្ជា និងវិក្ក័យបត្រត្រឹមត្រូវ។



## ៣-បាត់បង់សមត្ថភាពការងារបណ្តោះអាសន្នទទួលបាន៖

- ប្រាក់បំណាច់ប្រចាំថ្ងៃ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃគិតចាប់ពីថ្ងៃទី២ទៅ រហូតដល់ជាសះស្បើយ។
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ស្មើនឹង ៥០% នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។



## ៤- បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទទួលបាន

**- ប្រាក់វិភាជន៍ (ប្រាក់ឧបត្ថម្ភបើកផ្តាច់)**

ចំពោះការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង២០% ប.ស.ស ផ្តល់ជូនជនរងគ្រោះតែម្តងគត់។

**- ប្រាក់ធនលាភ (ឧបត្ថម្ភត្រីមាស)**

ចំពោះការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ចាប់ពី ២០% ឡើង ប.ស.ស ផ្តល់ជូនជនរងគ្រោះរៀងរាល់ ៣ខែម្តង បើកឱ្យជនរងគ្រោះអស់មួយជីវិត ករណីតម្រូវមានអ្នកចាំថែរក្សា មានសិទ្ធិទទួលបាន៥០% នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។



## ៥-សេវាបុននីតិសម្បទា

ផ្តល់ឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតស្របទៅតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស នឹងទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ៦-អ្នកទទួលរងហានិភ័យការងាររហូតដល់ស្លាប់

+ សោហ៊ុយដឹកសពដល់ផ្ទះជនរងគ្រោះ



+ អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍សោហ៊ុយបូជាសព ដែលមានចំនួន ៤.០០០.០០០ (បួនលាន)រៀល។ ប្រាក់វិភាជន៍នេះ ត្រូវផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។



+ សម្រាប់អ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះ ៖

- ករណីនៅលីវ ផ្តល់ប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬចាស់ជរានៅក្នុងបន្ទុករបស់ជនរងគ្រោះ ត្រូវមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ (មានអាយុចាប់ពី ៥៥ឆ្នាំឡើងទៅ)
- ករណីមិនមានសំបុត្រអាពាហ៍ពិពាហ៍ មិនផ្តល់ប្រាក់ឧបត្ថម្ភជូនប្តី ឬប្រពន្ធ និងកូនឡើយ (ប៉ុន្តែផ្តល់ជូនដូចករណីនៅលីវ) ។
- ករណីមានសំបុត្រអាពាហ៍ពិពាហ៍ផ្តល់ប្រាក់ឧបត្ថម្ភជូន ប្តី ឬប្រពន្ធមួយជីវិត ប្រសិនជាមិនមានចំណងអាពាហ៍ពិពាហ៍ជាថ្មីនិងកូនឧបត្ថម្ភដល់អាយុ១៨ឆ្នាំ បើនៅរៀនឧបត្ថម្ភដល់អាយុ២១ឆ្នាំ និងផ្តល់ជូនឪពុកម្តាយ ឬចាស់ជរា(អាយុចាប់ពី៥៥ឆ្នាំឡើងទៅនៅក្នុងបន្ទុករបស់ជនរងគ្រោះត្រូវមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ។

